# គោលនយោបាយស្តីពីការចូលរួមរបស់ជនពិការ

ស្ថាប័នតុលាការរដ្ឋ Maine មិនអត់ឱនចំពោះការរើសអើងគ្រប់ទម្រង់ទៅលើជនពិការឡើយ។ ការរើសអើងទៅលើជនពិការជាការរំលោភលើសិទ្ធិពលរដ្ឋរបស់បុគ្គល បំផ្លាញបូរណភាពនៃប្រព័ន្ធតុលាការ និងកន្លែងធ្វើការ និងប៉ះពាល់យ៉ាងអវិជ្ជមានទៅលើការផ្តល់យុត្តិធម៌ដោយស្មើភាព។ លើសពីនេះទៀត ការចូលរួមក្នុងគណៈវិនិច្ឆ័យគឺជាសិទ្ធិ និងទំនួលខុសត្រូវរបស់ពលរដ្ឋទាំងអស់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

គោលនយោបាយរបស់ស្ថាប័នតុលាការរដ្ឋ Maine ចែងថា៖

• កម្មវិធី សកម្មភាព សេវា និងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការ នឹងអាចប្រើបានយ៉ាងពេញលេញដោយជនពិការ ដូចត្រូវបានតម្រូវដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ព្រមទាំងច្បាប់ស្តីពីពលរដ្ឋអាមេរិកពិការ (Americans with Disabilities Act) ច្បាប់ស្តីពីការស្តារនីតិសម្បទា (Rehabilitation Act) ឆ្នាំ1973 និងច្បាប់ស្តីពីសិទ្ធិមនុស្ស (Human Rights Act) នៃរដ្ឋ Maine។
• បុគ្គលិកទាំងអស់នៃប្រព័ន្ធតុលាការនឹងផ្តល់សេវាភ្លាមៗ ប្រកបដោយការគួរសម និងដោយស្មើភាពដល់បុគ្គលគ្រប់រូប រួមទាំងជនពិការ និងរាយការណ៍នូវរាល់ឧប្បទ្ទវហេតុនៃការរើសអើងទៅលើបុគ្គលដោយសារពិការភាព។
• ឱកាសចូលរួមក្នុងគណៈវិនិច្ឆ័យនឹងមិនត្រូវបានបដិសេធ ឬរឹតត្បិតដោយសារពិការភាពឡើយ។
• បណ្តឹងពីបទរើសអើងដោយសារពិការភាពនឹងត្រូវបានឆ្លើយតបភ្លាមៗ ហើយកិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងនឹងត្រូវបានធ្វើឡើង ដើម្បីដោះស្រាយបណ្តឹងទាំងអស់ឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។
• ជនពិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងមិនត្រូវបានរើសអើងដោយសារពិការភាពឡើយ ទាក់ទងនឹងនីតិវិធីស្នើសុំការងារ ដូចជា ការជ្រើសរើសបុគ្គលិក ការដំឡើងតំណែង ឬការបញ្ចប់កិច្ចសន្យាការងារនិយោជិត ការបណ្តុះបណ្តាលអំពីការងារ ការផ្តល់សំណងដល់និយោជិត ឬលក្ខខណ្ឌផ្សេងទៀត និងបុព្វសិទ្ធិនៃការងារ និង
• បុគ្គលិកទាំងអស់នៃស្ថាប័នតុលាការនឹងទទួលបានការបណ្តុះបណ្តាល ដើម្បីអាចឲ្យពួកគេឆ្លើយតបនឹងទំនួលខុសត្រូវដែលបង្កើតឡើងដោយគោលនយោបាយនេះ និងដើម្បីជួយធ្វើឲ្យពួកគេឆាប់យល់អំពីតម្រូវការរបស់ជនពិការ។

ដើម្បីអភិវឌ្ឍគោលនយោបាយទាំងនេះ ស្ថាប័នតុលាការត្រូវអនុវត្តបញ្ញត្តិដូចខាងក្រោម៖

## 1. លទ្ធភាពរូបវន្តក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតុលាការ

ស្ថាប័នតុលាការរដ្ឋ Maine ទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ក្នុងការផ្តល់លទ្ធភាពរូបវន្តពេញ

លេញក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតុលាការ និងកំណត់តំបន់អាទិភាពដូចខាងក្រោម នៅក្នុងការផ្តល់លទ្ធភាពនោះ ក្នុងរយៈពេលអន្តរកាល មុនពេលមានលទ្ធភាពពេញលេញ៖

- ផ្លូវចូល ច្រកចូល និងកន្លែងចតរថយន្ត
- ការិយាល័យក្រឡាបញ្ជី រួមទាំងបញ្ជរសេវាសាធារណៈ
- បន្ទប់សវនាការ
- កន្លែងពិភាក្សាសម្រេចរបស់គណៈវិនិច្ឆ័យ
- បន្ទប់ទឹក

**2. ការសម្របសម្រួល ព្រមទាំងជំនួយ និងសេវាបន្ទាប់បន្សំ**

ស្ថាប័នតុលាការទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់ការសម្របសម្រួលសមស្រប និងផ្តល់ជំនួយ និងសេវាបន្ទាប់បន្សំនានា ដើម្បីធានាបាននូវការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនពិការ ដែលមានការទាក់ទងជាមួយនឹងប្រព័ន្ធតុលាការ។ ស្ថាប័នតុលាការផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើត និងទទួលបានភ្លាមៗនូវជំនួយ និងសេវាបន្ទាប់បន្សំចាំបាច់ រហូតដល់ជំនួយ និងសេវាបន្ទាប់បន្សំសមស្របអាចរកបាននៅតុលាការទាំងអស់។ ក្នុងចន្លោះពេលនេះ កិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងនឹងត្រូវធ្វើឡើង ដើម្បីផ្តល់ការសម្របសម្រួល ព្រមទាំងជំនួយ និងសេវាបន្ទាប់បន្សំ ដើម្បីធានានូវការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនពិការនៅក្នុងប្រព័ន្ធតុលាការ។

ការសម្របសម្រួលនឹងត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃដល់ជនពិការ។ ក្នុងករណីភាគច្រើន ការបង្ហាញលិខិតបញ្ជាក់អំពីពិការភាពមិនត្រូវបានតម្រូវឡើយ។ ឧទាហរណ៍នៃការសម្របសម្រួលដែលអាចត្រូវបានផ្តល់រួមមានដូចខាងក្រោម៖

- អ្នកបកប្រែភាសាសញ្ញា ផ្ទាល់មាត់ និងភាសាកាយវិការ និងការមើលមាត់ដែលមានសមត្ថភាព
- សេវាប្រតិចារិកតាមពេលពិត (CART)
- ឧបករណ៍ជំនួយដល់ការស្តាប់
- ការផ្តល់ឯកសារតុលាការដែលសរសេរអក្សរធំៗ និងជាអក្សរប្រាយ
- កាសែ្សតម៉ាញ៉េ ឧបករណ៍ថតសំឡេង និងឌីសកុំព្យូទ័រ
- ឧបករណ៍បញ្ជូនសារ៖ Maine Relay 711 និងទូរស័ព្ទមានសំឡេងខ្លាំង
- ការរៀបចំដែលធ្វើឡើងដើម្បីធានាថា សុនខនាំផ្លូវត្រូវបានអនុញ្ញាតឲ្យនៅជាមួយម្ចាស់ជាជនពិការរបស់វាគ្រប់ពេលវេលា។

ស្ថាប័នតុលាការក៏អាចផ្តល់ការសម្របសម្រួលសមស្របផ្សេងទៀត ដែលចាំបាច់ដើម្បីអនុញ្ញាត ឲ្យជនពិការចូលរួមយ៉ាងពេញលេញ ឬគោរពតាមសកម្មភាពរបស់តុលាការផងដែរ។

### 3. ធនធានហិរញ្ញវត្ថុ
ស្ថាប័នតុលាការនឹងស្វែងរកធនធានហិរញ្ញវត្ថុចាំបាច់យ៉ាងសកម្ម និងធ្វើការងារយ៉ាងឃ្មាតខ្មី ដើម្បីលុបបំបាត់ឧបសគ្គទាំងអស់ដែលមានចំពោះជនពិការ។

### 4. នីតិវិធីស្នើសុំការសម្របសម្រួលទូទៅ
ការសម្របសម្រួលនឹងអាចរកបាន និងត្រូវស្នើសុំនៅពេលដែលអាចធ្វើទៅបាន។ ប្រសិនបើចាំបាច់ត្រូវធ្វើសំណើសុំ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

a. សំណើសុំការសម្របសម្រួលអាចធ្វើទៅក្រឡាបញ្ជីតុលាការ ដែលកិច្ចដំណើរការនីតិវិធីនឹងត្រូវធ្វើឡើង។
b. សំណើសុំការសម្របសម្រួលទាំងអស់ត្រូវបរិយាយអំពីការសម្របសម្រួល ដែលស្នើសុំ និងប្រសិនបើមិនច្បាស់ អំពីមូលហេតុដែលសំណើត្រូវបានធ្វើឡើង។
c. រាល់ការបដិសេធរបស់ចៅក្រម ឬមន្ត្រីតុលាការដែលមានការអនុញ្ញាតត្រឹមត្រូវ ចំពោះការសម្របសម្រួលដែលបានស្នើសុំ នឹងត្រូវភ្ជាប់មកជាមួយនូវសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរនូវមូលហេតុនៃការបដិសេធ។

### 5. ការចូលរួមក្នុងគណៈវិនិច្ឆ័យរបស់ជនពិការ

a. ចៅក្រម ឬបុគ្គលិកតុលាការផ្សេងទៀតត្រូវធ្វើការរៀបចំគ្រប់បែបយ៉ាង ដែលចាំបាច់ដើម្បីសម្របសម្រួលយ៉ាងសមស្របដល់សមាជិកគណៈវិនិច្ឆ័យជាជនពិការ ដើម្បីធានាបាននូវការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពនៅគ្រប់ដំណាក់កាលនៃដំណើរការកោះអញ្ជើញ តម្រង់ទិស ណែនាំ និងពិភាក្សាសម្រេចរបស់គណៈវិនិច្ឆ័យ។
b. អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានកោះអញ្ជើញឲ្យធ្វើជាសមាជិកគណៈវិនិច្ឆ័យ អាចត្រូវបានលើកលែងឲ្យរួចផុតពីកាតព្វកិច្ចចូលរួមក្នុងគណៈវិនិច្ឆ័យ ដោយផ្អែកលើពិការភាពបាន លុះត្រាតែពួកគេមិនមានសមត្ថភាពជួយសម្របសម្រួលដោយសមស្រប ឬជួយបំពេញភារកិច្ចរបស់ខ្លួនជាសមាជិកគណៈវិនិច្ឆ័យបាន។

### 6. លក្ខខណ្ឌតម្រូវរបស់មេធាវី
មេធាវីនៅក្នុងរឿងក្តីគួរជូនដំណឹងដល់តុលាការភ្លាមៗពេលបានដឹងថា ជនពិការមានការពាក់ព័ន្ធនឹងរឿងក្តី និងត្រូវការការសម្របសម្រួលពីតុលាការ។

## 7. នីតិវិធីដោះស្រាយបណ្ដឹង សាទុក្ខ

ស្ថាប័នតុលាការបានអនុម័តនីតិវិធីដោះស្រាយបណ្ដឹងសាទុក្ខ និងទម្រង់បណ្ដឹង/បណ្ដឹងសាទុក្ខសុំការសម្របសម្រួល ដើម្បីអនុវត្តគោលនយោបាយដែលបញ្ជាក់នៅក្នុងឯកសារនេះ។

a. លិខិតជូនដំណឹងមួយច្បាប់របស់តុលាការអំពីអនុលោមភាព នីតិវិធីដោះស្រាយបណ្ដឹងសាទុក្ខ និងទម្រង់បណ្ដឹង/បណ្ដឹងសាទុក្ខសុំការសម្របសម្រួល ត្រូវមាននៅការិយាល័យក្រឡាបញ្ជីនីមួយៗ និងត្រូវបានផ្ដល់ដល់បុគ្គលគ្រប់រូប

b. តុលាការត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីដោះស្រាយបណ្ដឹងឲ្យពេញចិត្តដល់ជនពិការ។

គ្មានបញ្ញត្តិណាមួយនៅក្នុងគោលនយោបាយនេះ ត្រូវបានបកស្រាយថាដាក់កំហិត ឬធ្វើឲ្យអសុពលភាពដល់ឧបាស្រ័យ សិទ្ធិ និងនីតិវិធីដែលត្រូវបានផ្ដល់ដល់ជនពិការ យោងតាមច្បាប់ថ្នាក់មូលដ្ឋាន រដ្ឋ ឬសហព័ន្ធឡើយ។